**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ: ៧៣៣......កប/ប្រក

# ប្រកាស

# ស្តីពី

# ការបង់ភាគទានហានិភ័យការងារនៃសហគ្រាស គ្រឹះស្ថានកាត់ដេរ និងស្បែកជើងសម្រាប់ឆ្នាំ២០០៩- ២០១០

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានីតិកាលទី ៤ នៃរដ្ឋសភា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០០៩ លើរបាយការណ៍របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- បានឃើញសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ១.-**

អត្រាភាគទានផ្នែកហានិភ័យការងារ ចំនួន ០.៨ ភាគរយ អនុលោមតាមប្រកាសលេខ

១០៨ កប/ប្រក ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ ត្រូវបានបន្ថយមកត្រឹម ០.៥ ភាគរយ សម្រាប់សហគ្រាស គ្រឹះស្ថានកាត់ដេរ និងស្បែកជើង។ អត្រាភាគទាននេះ ត្រូវបានអនុវត្តសម្រាប់រយៈពេល ០២ ឆ្នាំ គឺឆ្នាំ២០០៩ និង២០១០។ ចំពោះភាគដែលនៅសល់ចំនួន ០.៣ ភាគរយ ត្រូវបានរដ្ឋជាអ្នកបង់ជំនួស។

**ប្រការ ២ .-**

ចំពោះសហគ្រាស គ្រឹះស្ថានកាត់ដេរ និងស្បែកជើង ដែលបានបង់ភាគទាន ០.៨ ភាគរយ រួចហើយសសម្រាប់បណ្តាខែដើមឆ្នាំ២០០៩ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវទូទាត់កាត់កងសម្រាប់ការបង់ភាគទានក្នុងខែបន្តបន្ទាប់តាមចំនួនទឹកប្រាក់ដែលលើសជាក់ស្តែងនៃខែទាំងនោះ។

**ប្រការ ៣.-**

សហគ្រាស គ្រឹះស្ថានកាត់ដេរ និងស្បែកជើង គឺបណ្តាសហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្នុងវិស័យកាត់ដេរ និងស្បែកជើង ដោយគិតរួមទាំងសហគ្រាស គ្រឹះស្ថានដេរប៉ាក់ ចាក់អាវ បោកគក់ និង បោះពុម្ព ដែលបម្រើដល់សហគ្រាសគ្រឹះស្ថានកាត់ដេរ និងស្បែកជើងផងដែរ។

**ប្រការ ៤ .-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩

**រដ្ឋមន្ត្រី**

**វង សូត**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប "
- កាលប្បវត្តិ និងឯកសារ